**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

*បពិត្រ ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!*

ក្រោយពីបានស្តាប់សេចក្តីថ្វាយនិងជូនដំណឹងរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទូលព្រះបង្គំ ជាខ្ញុំ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល មានក្តីក្តុកក្តួលរន្ធត់ចិត្តឥតឧបមា ដោយ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរៈក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាព ជាតិខ្មែរ** ព្រះអង្គទ្រង់បានយាងចូលទីវង្គត នាថ្ងៃ១៥រោច ខែភទ្របទ ឆ្នាំរោងចត្វាស័ក ព.ស ២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា គ.ស២០១២ វេលាម៉ោង០១:២០នាទីរំលងអាធ្រាត្រ (ម៉ោងនៅរាជធានីភ្នំពេញ) ក្នុងព្រះជន្មាយុ៩០ព្រះវស្សា ដោយព្រះជរាពាធនៅមន្ទីរពេទ្យ ទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។

ក្នុងឱកាសប្រកបដោយក្តីខ្សឹកខ្សួលរំជួលចិត្តក្រៀមក្រំជាអនេកនេះ ទូលព្រះបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ កងយោធពលខេមរភូមិន្ទ សូមព្រះបរមរាជានុញ្ញាត សម្តែងថ្វាយនូវសមានទុក្ខដ៏មហាជ្រាលជ្រៅជាទីបំផុត ព្រមទាំងក្តីសង្វេគដ៏មហាធំធេង និងពោរពេញដោយក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យជាអនេកប្បការ ចំពោះ **អង្គព្រះមហាវីរក្សត្រ ព្រះវររាជបិតា** ជាទីគោរពសក្ការៈស្មើជីវិត ដែលព្រះអង្គទ្រង់ដាក់ព្រះជន្មសង្ខារលាចាកលោក ចាកពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ជាកូន ចៅ ចៅទួត ចៅលួតរបស់ព្រះអង្គ ដែលជានិច្ចកាលដង្ហែ យ៉ាងស្មោះស្ម័គ្រ ប្រកបដោយកក្តីភាពយ៉ាងជ្រាលជ្រៅបំផុតតាម ព្រះរាជគំរូវីរភាព ដ៏ថ្លៃថ្លា របស់ **អង្គសម្តេចឪ** ជារៀងរហូតមក។

បពិត្រ ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈ!

ការបាត់បង់នូវព្រះរាជវត្តមានដ៏ឧត្តុង្គឧត្តម នៃ **អង្គសម្តេចព្រះមហាវីរក្សត្រព្រះវររាជបិតា ឯករាជ្យជាតិខ្មែរ** នាឱកាសនេះគឺជាការបាត់បង់នូវ **អង្គព្រះអតីតព្រះមហាក្សត្រខ្មែរ** ដ៏មហាឆ្នើមមួយព្រះអង្គ ដែលជានិច្ចកាលទ្រង់បានបំពេញ ព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ប្រកបដោយព្រះបញ្ញាញាណភ្លឺថ្លា វាងវៃគ្រប់កាលៈទេសៈ។ ថ្វីបើព្រះរូប ព្រះកាយរបស់ **ព្រះអង្គ** ទម្លាបេក្ខន្ធយាងទៅកាន់បរលោកហើយក្តី ក៏ព្រះរាជលំអានព្រះវីរគំរូដ៏ល្អឆ្នើមរបស់ **អង្គសម្តេចឪ** ជាអម្ចាស់ទ្រង់ស្ថិតនៅជានិច្ចក្នុងបនសិការ និងឆន្ទៈ របស់ទូលព្រះបង្គំ ជាខ្ញុំ ទាំងអស់គ្នាជាថ្នាក់ដឹកនាំក្រសួងការពារជាតិ និងនាយទាហាន នាយទាហានរងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ហើយពិតជានឹងស្ថិតស្ថេរគង់វង្ស ជាអមតៈ។

ជាមួយនឹងសមានទុក្ខដ៏ក្រៀមក្រំរកទីបំផុតគ្មាននេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំអោនកាយឧទ្ទិសបួងសួងដល់ដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ជាតិខ្មែរ** សូមព្រះអង្គទ្រង់យាងចាប់បដិសន្ធិក្នុង ព្រះបរមសុគតិភព គ្រប់ៗព្រះជាតិ កុំបី ឃ្លៀងឃ្លាត ក្លាយជាបការៈដ៏ទៃឡើយ។

សូម **ព្រះករុណា** ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ប្រោសព្រះរាជ មេត្តាទទួល នូវអភិវន្ទនកិច្ចនិងកតញ្ញូតាធម៌ ដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំ ជាខ្ញុំ ទាំងអស់គ្នា។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ តុលា ឆ្នាំ ២០១២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ ទៀ បាញ់

ទីស្តីការ ក្រសួងការពារជាតិ ទូរស័ព្ទ-ទូរសារ : (៨៥៥) ០២៣ ៨៨៣២៧៤ E.Mail : Minadef@camnet.com.kh